ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខៈ ០០៥ ......សហវ.....

រាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

# សារាចរណែនាំ
# ស្តីពីការអនុវត្តថវិការាជធានី ខេត្ត ឆ្នាំ ២០១១

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ១២១០ / ០១៧ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១០ ។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ១៧០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ និងអនុក្រឹត្យលេខ ១៦៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០ ស្តីពីការបែងចែកចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១១។ ដើម្បីអោយការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ មានដំណើរការប្រកបដោយភាពស័ក្តិសិទ្ធិ ប្រសិទ្ធភាព និងសំរេចបានតាមគោលដៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំលើការអនុវត្តថវិការបស់រាជធានី ខេត្ត សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដែលមានតាមលំដាប់លំដោយដូចតទៅ ៖

## ក.អំពីចំណូល

### ១.ចំណូលសារពើពន្ធ

ចំពោះមុខសញ្ញាចំណូលសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូលសម្រាប់ជាគុណប្រយោជន៍នៃថវិការាជធានី ខេត្ត រាជធានី ខេត្ត ត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយ និងនីតិវិធីប្រមូលចំណូលរបស់មន្ត្រីពន្ធដារអោយបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន និងត្រូវរួមចំណែកដាក់ចេញវិធានការដាក់ស្តែងសម្រាប់ប្រភេទពន្ធដារនីមួយៗ ដើម្បីតម្រូវអោយអ្នកជាប់ពន្ធបង់ពន្ធបានត្រឹមត្រូវគ្រប់គ្រាន់ និងទាន់ពេលវេលា។ទន្ទឹមនឹងនោះ រាជធានី ខេត្ត ត្រូវចាត់អោយមានមន្ត្រីទទួលបន្ទុកប្រមូលទិន្នន័យ ស្ថិតិ និងកម្រងព័ត៌មាន ដែលជាមូលដ្ឋានក្នុងការប្រមូលពន្ធដារ សម្រាប់ជាគុណប្រយោជន៍ដល់ថវិការាជធានី ខេត្ត ដើម្បីជួយដល់មន្ត្រីពន្ធដារក្នុងការប្រមូលចំណូល និងធ្វើជាឯកសារបង្អែកក្នុងការរៀបចំគម្រោងចំណូលពន្ធដារ សម្រាប់ឆ្នាំនីមួយៗ ។

### ២.ចំណូលមិនមែនសារពើពន្ធ

ចំពោះចំណូលមិនមែនពន្ធសារពើពន្ធ ដែលច្បាប់បានអនុញ្ញាតអោយប្រមូល សម្រាប់ថវិការាជធានី ខេត្ត រាជធានី ខេត្តត្រូវយកចិត្តទុកដាក់ស្រាវជ្រាវកំណត់មុខសញ្ញាចំណូល ដែលត្រូវប្រមូលបង់ចូលរតនាគារអោយអស់មិនត្រូវទុកចំណូលខ្លះ នៅដោយឡែក សម្រាប់ចំណាយដោយឡែកក្រៅពីគម្រោងចំណាយប្រចាំឆ្នាំឡើយ ។

ចំពោះចំណូលមិនមែនពន្ធសារពើពន្ធដទៃទៀត ដែលរាជធានី ខេត្ត បានប្រមូលក្រៅពីការអនុញ្ញាតដោយច្បាប់ក៏ត្រូវបង់ចូលថវិការាជធានី ខេត្តដែរ ជៀសវាងទុកចំណូលនោះដោយឡែកសម្រាប់ចំណាយដោយឡែកគ្មានតម្លាភាព ។

ចំពោះមុខសញ្ញាចំណូលដែលបានកំណត់រួចហើយ បើក្នុងលក្ខណៈដែលត្រូវប្រមូលតាមវិធីដេញថ្លៃជាសាធារណៈនោះ ត្រូវធ្វើអោយមានតម្លាភាពពិតប្រាកដ មិនត្រូវបង្កើតការដេញថ្លៃតែរូបភាពនោះទេ ទន្ទឹមនោះត្រូវយកចិត្តទុកដាក់ជំរុញការបង់ចំណូលអោយបានត្រឹមត្រូវតាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា ។

## ៣.ចំណូលឧបត្ថម្ភពីថវិការដ្ឋ

ចំពោះរាជធានី ខេត្ត ដែលត្រូវបំពេញតុល្យភាពដោយការឧបត្ថម្ភពីថវិការដ្ឋ ទោះបីបានកត់ត្រាតួលេខចំណូលឧបត្ថម្ភពីថវិការដ្ឋ[illegible]នៅក្នុងគម្រោងថវិការបស់ខ្លួនក៏ដោយ ក៏មិនមានន័យថា ថវិការដ្ឋត្រូវតែជាច់ខាតឧបត្ថម្ភតាមចំនួននោះទេ ។ ចំណូលឧបត្ថម្ភពីថវិការដ្ឋ គឺត្រូវពិនិត្យជូនរាជធានី ខេត្ត ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃតុល្យភាពថវិការដ្ឋ និងទៅតាមសភាពការណ៍ជាក់ស្តែងនៃការអនុវត្តចំណូល ចំណាយថវិការបស់រាជធានី ខេត្ត ។

## ៣.១ ចំណូលឧបត្ថម្ភតុល្យភាពពីថវិការដ្ឋ

ចំពោះចំណូលនេះ រាជធានី ខេត្ត ត្រូវធ្វើសំណើសុំឧបត្ថម្ភតុល្យភាពប្រចាំត្រីមាសនីមួយៗ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈក្រសួងមហាផ្ទៃ ។ នៅដើមត្រីមាសទី ១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងផ្តល់ថវិកាឧបត្ថម្ភជូនរាជធានី ខេត្ត ដោយមិនបាច់មានការស្នើសុំទេ ។ ដោយឡែកសម្រាប់ត្រីមាសទី ២ ទី ៣ និងទី ៤ រាជធានី ខេត្ត ត្រូវធ្វើសំណើសុំថវិកាឧបត្ថម្ភតុល្យភាពនៅដើមខែ នៃចុងត្រីមាសមុន សម្រាប់ត្រីមាសបន្ទាប់ដោយភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម :

- របាយការណ៍អនុវត្តចំណូល ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់រតនាគាររាជធានី ខេត្ត
- របាយការណ៍ប៉ាន់ស្មានចំណូលសម្រាប់ត្រីមាសបន្ទាប់ ដោយមានបែងចែកតាមខែនីមួយៗ ដោយភ្ជាប់នូវឯកសារសម្រាប់គាំទ្រ
- របាយការណ៍អនុវត្តចំណាយ ជាក់ស្តែងដែលមានហត្ថលេខាបញ្ជាក់របស់អាណាប័ក និងអាណាត្តិបើកប្រាក់(ថតចម្លង) ដែលអាណាប័កបានចុះហត្ថលេខារួច
- របាយការណ៍ប៉ាន់ស្មានចំណាយសម្រាប់ត្រីមាសបន្ទាប់ ដោយភ្ជាប់តាមនូវឯកសារសម្រាប់គាំទ្រ (ឯកសារលទ្ធកម្មសាធារណៈដែលពាក់ព័ន្ធដល់ការទូទាត់)

## ៣.២ ចំណូលឧបត្ថម្ភពីថវិការដ្ឋសំរាប់វិនិយោគសាធារណៈ

ចំណូលនេះ គ្រាន់តែជាការផ្ទេរឥណទានថវិការដ្ឋសម្រាប់អនុវត្តនូវកម្មវិធីចំណាយវិនិយោគសាធារណៈនៅក្នុងថវិការាជធានី ខេត្ត ដូច្នេះពេលស្នើសុំគឺរាជធានី ខេត្តត្រូវធ្វើសំណើត្រង់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតែម្តង។ ការស្នើនេះ ចែកចេញជាពីរយ៉ាង ៖

### ទី១.ឧបត្ថម្ភសម្រាប់មូលនិធិបដិភាគ

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវគម្រោងកម្មវិធីវិនិយោគសាធារណៈ នៃហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ ដែលត្រូវអនុវត្តនៅរាជធានី ខេត្ត ។

### ទី២.ឧបត្ថម្ភវិនិយោគដោយថវិការដ្ឋ

ផ្អែកលើតួលេខដែលបានគ្រោងក្នុងសៀវភៅថវិការាជធានី ខេត្ត ឬ ប្រកាសបន្ថែមឥណទានត្រូវធ្វើសំណើដោយភ្ជាប់មកជាមួយនូវឯកសារដែលបានធ្វើលទ្ធកម្មសាធារណៈរួចតាមការដ្ឋាននីមួយៗ។

# ខ.អំពីចំណាយ

## ១.ចំណាយចរន្ត:

ចំណាយចរន្តត្រូវអនុវត្តអោយបានម៉ឺងម៉ាត់ ទៅតាមគោលការណ៍ និងនីតិវិធីដូចគ្នា នៃចំណាយថវិការដ្ឋដែលពោលគឺ ៖

- អំពីចំណាយបៀវត្សត្រូវអនុវត្តតាមរយៈភ្នាក់ងារបើកផ្តល់ ។ ចំពោះបៀវត្សមូលដ្ឋានប្រាក់កម្រៃបុគ្គលិកអណ្តែត និងភ្នាក់ងារជាប់កិច្ចសន្យាត្រូវអនុវត្តតាមតារាងបើកប្រាក់ដែល ចេញដោយក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងបានផ្តល់ទិដ្ឋាការដោយរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈរួចហើយ ។ ចំណែកប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ២១៤ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបានគ្រោងនៅក្នុង អនុគណនី ៦៤៤២ (លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ)

- អំពីចំណាយតូចតាច និងចំណាយចាំបាច់បន្ទាន់ គឺត្រូវអនុវត្តតាមរដ្ឋទេយ្យបុរេប្រទាន ដែលកំណត់ឡើងដោយដីការបស់រាជធានី ខេត្ត ។ ពេលដកប្រាក់ពីរតនាគារ រដ្ឋទេយ្យករត្រូវមានប័ណ្ណដកប្រាក់ និងលិខិតឧទ្ទេសនាមរបស់អង្គភាព (ពុំចាំបាច់ធ្វើលិខិតស្នើសុំឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទេ) ។ ចំពោះការចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន សម្រាប់ថវិកាឆ្នាំ ២០១១នេះ អភិបាលរាជធានី ខេត្ត ត្រូវពិភាក្សាអោយបានល្អិតល្អន់ជាមួយប្រធានរតនាគាររាជធានី ខេត្ត និងប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ក្នុងការកំណត់ទំហំឥណទាន និងចំនួនជុំបង្វិល ដើម្បីធានាអោយឥណទានរដ្ឋទេយ្យបុរេប្រទានអាចបំរើបានទាន់ពេលវេលា ទាំងនៅរដ្ឋបាលថ្នាក់រាជធានី ខេត្ត និងទាំងនៅរដ្ឋបាលថ្នាក់ ក្រុង ស្រុក ខណ្ឌ ក្នុងពេលដែល ក្រុង ស្រុក ខណ្ឌ ពុំទាន់មានថវិការបស់ខ្លួនតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- អំពីចំណាយចរន្តផ្សេងៗទៀត គឺត្រូវអនុវត្តតាមនីតិវិធីទូទាត់ត្រង់ជូនអ្នកផ្គត់ផ្គង់ ក្រោយពេលដែលទំនិញ ឬសេវានានា ត្រូវបានអនុវត្តរួចហើយ ។

- ចំពោះជំពូក ០៩ (ចំណាយមិនបានគ្រោងទុក) រាជធានី ខេត្ត មិនត្រូវអនុវត្តចំណាយជំពូកនេះដោយផ្ទាល់ទេ ។ នៅពេលមានតម្រូវការចំណាយរាជធានី ខេត្ត ត្រូវធ្វើសំណើសុំការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីបង្វែរឥណទានពីជំពូកនេះ ទៅជាប្រយោជន៍ដល់ជំពូកចំណាយដទៃទៀតទៅតាមតម្រូវការចំណាយជាក់ស្តែងនីមួយៗ ជាពិសេសអាទិភាពសម្រាប់តម្រូវការប្រាក់បៀវត្ស និងការងារអភិវឌ្ឍន៍គុណប្រយោជន៍រាជធានី ខេត្ត ។

## ២.ចំណាយជាមូលធនៈ

ចំពោះការចំណាយជាមូលធន គឺចែកចេញជាពីរ ៖

### ទី១.ចំណាយសំរាប់មូលនិធិបដិភាគ

ក្នុងពេលអនុវត្តរាជធានី ខេត្ត ត្រូវធ្វើអាណត្តិដោយគ្រាន់តែភ្ជាប់នូវគម្រោងកម្មវិធីវិនិយោគសាធារណៈនៃហិរញ្ញប្បទានពីក្រៅប្រទេសតែប៉ុណ្ណោះ។ រតនាគាររាជធានី ខេត្ត ត្រូវបើកផ្តល់ ឬផ្ទេរឥណទាននេះ ទៅក្នុងគណនីម្ចាស់ជំនួយនៅរតនាគាររាជធានី ខេត្ត ឬធនាគារ (បើមាន) ។

### ទី២.ចំណាយវិនិយោគ

ចំណាយវិនិយោគ ទោះជាហិរញ្ញប្បទានដោយថវិការាជធានី ខេត្ត ឬហិរញ្ញប្បទានដោយថវិការដ្ឋឧបត្ថម្ភក៏ដោយគឺ ត្រូវតែបំពេញបែបបទ និងអនុវត្តអោយបានត្រឹមត្រូវទៅតាមនីតិវិធីលទ្ធកម្មសាធារណៈជាធរមាន និងធ្វើអាណត្តិទូទាត់អោយបានត្រឹមត្រូវតាមការិយបរិច្ឆេទដែលបានកំណត់ក្នុងសៀវភៅបន្ទុក ឬកិច្ចសន្យា ។

## ៣.ការកែតម្រូវគម្រោងថវិកា

យោងប្រការ ១២ នៃប្រកាសលេខ ២០៣ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីបទបញ្ជាថវិការបស់រាជធានី ខេត្តបានចែងថា នៅក្នុងឆ្នាំថវិកាប្រសិនបើចំណូលជាក់ស្តែងនៃថវិការបស់រាជធានី ខេត្ត បានកើនឡើងខ្ពស់ជាង ពីគម្រោងចំណូលប្រចាំឆ្នាំ ដែលបានគ្រោងទុកនោះឥណទានចំណាយថវិកាអាចត្រូវបង្កើនឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅតាមកំរិតចំណូលលើសដែលបានចុះកិច្ចបញ្ជីការ ។

ដូច្នេះ នៅត្រីមាសទី ៤ រាជធានី ខេត្ត ត្រូវពិនិត្យការអនុវត្តចំណូលរបស់ខ្លួន ដោយមានមូលដ្ឋានជាក់លាក់ ដែលអាចប្រមូលចំណូលបានយ៉ាងពិតប្រាកដ រួចប្រៀបធៀបជាមួយគម្រោងចំណូលប្រចាំឆ្នាំ ។ ប្រសិនបើមានចំណូលលើសពីគម្រោងចំណូលប្រចាំឆ្នាំរាជធានី ខេត្ត អាចស្នើសុំបន្ថែមលើគម្រោងចំណាយប្រចាំឆ្នាំ សម្រាប់ចំណាយជាគុណប្រយោជន៍របស់រាជធានី ខេត្ត ដែលជាចំណាយសម្រាប់វិនិយោគអភិវឌ្ឍន៍រាជធានី ខេត្ត ហើយរាជធានី ខេត្ត ត្រូវផ្ញើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវគម្រោងចំណាយលំអិតតាមការដ្ឋាននីមួយៗ ។

## គ.ការបង្វែរឥណទាន

ការបង្វែរ(និយ័តភាព) ឥណទានត្រូវបានអនុញ្ញាតឲ្យអនុវត្តចាប់ពីត្រីមាសទី២ ។ ក្នុងករណីមានការចាំបាច់និយ័តភាពថវិកាពីអនុគណនីមួយ ទៅអនុគណនីមួយ ពីគណនីមួយ ទៅគណនីមួយ និងពីជំពូកមួយ ទៅជំពូកមួយផ្សេងទៀតនោះ រាជធានី ខេត្ត ត្រូវផ្ញើសំណើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ចំណាយជាក់ស្តែងដែលបានអនុវត្តកន្លងមក និងគម្រោងប៉ាន់ស្មានចំណាយលំអិតដល់បំណាច់ឆ្នាំ ព្រមទាំងឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធការស្នើសុំនិយ័តភាព។

## ឃ.ការរៀបចំកម្មវិធីចំណូល ចំណាយ

ផ្អែកលើគម្រោងថវិកាប្រចាំឆ្នាំ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសជូន រាជធានី ខេត្តទាំងអស់ត្រូវរៀបចំកម្មវិធីចំណូល ចំណាយថវិកាប្រចាំត្រីមាសនិងត្រូវផ្ញើកម្មវិធីចំណូល ចំណាយនោះទៅរតនាគាររាជធានី ខេត្ត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ យ៉ាងយូរបំផុតមួយសប្តាហ៍នៃដើមត្រីមាសនីមួយៗ ។ ដោយឡែកសម្រាប់ត្រីមាសទី ២ ទី៣ និងទី៤ ពេលផ្ញើកម្មវិធីចំណូល ចំណាយប្រចាំត្រីមាសមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ គឺជាច់ខាតត្រូវតែភ្ជាប់មកជាមួយនូវរបាយការណ៍ស្តីពីការអនុវត្តថវិកានៃត្រីមាសមុន ។ កម្មវិធីចំណូល ចំណាយប្រចាំត្រីមាស និងជាឯកសារគោល ដើម្បីវិភាគក្នុងការផ្តល់ឧបត្ថម្ភធនលំនឹងពីថវិការដ្ឋ ។

## ង.ការផ្ទេរប្រតិភូកម្មថវិកាដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្ត

សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកាឆ្នាំ ២០១១ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានធ្វើសេចក្តីប្រកាសថវិកាជូនរាជធានី ខេត្ត ដោយមានបែងចែកលំអិតទៅតាម ក្រុង ស្រុក ខណ្ឌ ចំណុះរាជធានី ខេត្តនីមួយៗ ដែលអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវជូនដំណឹងដល់រដ្ឋបាល ក្រុង ស្រុក ខណ្ឌទាំងនោះ បានជ្រាបជាពត៌មាន ។

យោងតាមសេចក្តីប្រកាសលេខ ៧៤០ សហវ.ប្រក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១០ ស្តីពីការបង្កើតថវិកាផ្នែកសម្រាប់ ក្រុង ស្រុក ខណ្ឌ ដែលរចនាសម្ព័ន្ធមានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញដីកាបែងចែកថវិកា និងផ្ទេរសិទ្ធិអាណាប័កទៅឲ្យអភិបាល ក្រុង ស្រុក ខណ្ឌ ណាដែលរចនាសម្ព័ន្ធមានការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ ហើយផ្ញើជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១ច្បាប់ និងរតនាគាររាជធានី ខេត្ត ០១ច្បាប់(ច្បាប់ដើម) ។

ត្រូវយកចិត្តទុកដាក់អនុវត្តផ្តល់ការចំណាយថវិកាតាមការបែងចែក ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានប្រកាសជូន ។

ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រធានរតនាគាររាជធានី ខេត្ត ត្រូវសហការយ៉ាងជិតស្និត ជាមួយនាយកទីចាត់ការហិរញ្ញវត្ថុរបស់សាលារាជធានី ខេត្ត ដើម្បីជួយគាំទ្រដល់មន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ នៃការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងអភិបាលនៃគណៈអភិបាល ក្រុង ស្រុក ខណ្ឌ ដែលបានទទួលការបែងចែកថវិកា និងអាណាប័កផ្ទេរសិទ្ធិពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ។

ក្នុងការអនុវត្តថវិការាជធានី ខេត្ត នាយកទីចាត់ការហិរញ្ញវត្ថុត្រូវធ្វើជាសេនាធិការអោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្នុងការរៀបចំរាល់សំណុំលិខិត ឯកសារទាំងអស់ដែលពាក់ព័ន្ធដល់ការងារជំនាញហិរញ្ញវត្ថុ ថវិកា ដើម្បីជំរុញអោយការអនុវត្តចំណូល និងចំណាយថវិការាជធានី ខេត្ត សំរេចបានត្រឹមត្រូវ និងប្រកបដោយប្រសិទ្ធភាព ។

ខាងលើនេះ គឺជាការណែនាំបន្ថែមក្នុងកិច្ចប្រតិបត្តិការថវិការាជធានី ខេត្តឲ្យចំទិសដៅ និងមានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១១ ដោយឡែកប្រកាសប្រកាសណែនាំស្តីពី កិច្ចប្រតិបត្តិការអនុវត្តថវិការាជធានី ខេត្ត លេខ ២០៥ ប្រក.សហវ.ថ ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលមិនផ្ទុយនឹងប្រកាសនេះ នៅរក្សាសុពលភាពដដែល ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**<u>កន្លែងទទួល:</u>**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ (ដើម្បីជូនជ្រាប)
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត
- គ្រប់សាខាពន្ធដាររាជធានី ខេត្ត
- (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ